# សុន្ទរកថា

## ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
## រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាប្រធាន
## ក្រុមការងារគ្រប់គ្រងគម្រោង FMIS
## ថ្លែងក្នុងពិធី

**“ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តដែលមិនមានធានាចំណាយដោយឡែកតាម FMIS ទាំងស្រុង, ពង្រីកការដាក់ឱ្យប្រើប្រាស់ FMIS នៅការដ្ឋានថ្មី, ពង្រីកការដាក់ឱ្យប្រើប្រាស់ FMIS Portal ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅសេសសល់ និង ពង្រីកសន្ធានកម្មទិន្នន័យរវាង FMIS ជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ”**

**នៅ សណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ**

**ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក**

**ពុទ្ធសករាជ ២៥៦៧ ថ្ងៃទី ០៦ ខែ កក្កដា គ្រិស្តសករាជ ២០២៣**

***ជាបឋម ខ្ញុំបាទសូមគោរព:***

- *ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *លោកស្រី **យុតសារណា ឡាម៉ា** នាយិកាធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ និង តំណាងក្រសួង-ស្ថាប័ន*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍*
- *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី និង អង្គពិធី ជាទីគោរព !*

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសជាអនេក ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** រាយការណ៍ជូនអង្គពិធីទាំងមូល អំពីវឌ្ឍនភាពក្នុងទិដ្ឋភាពចម្បងនៃការអនុវត្តគម្រោង **FMIS**

ដែលក្រុមការងារគ្រប់គ្រងគម្រោង **FMIS** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានខិតខំពុះពារយ៉ាងម៉ឺងម៉ាត់ ក្នុងការសម្រេចឱ្យបាននូវគោលដៅធំៗ ស្របតាម “***ផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ ២០២១-២០២៥ និង ផែនការសកម្មភាពរួមដំណាក់កាលទី៤ ២០២៣-២០២៧ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ***” ។ ការសម្រេចបានគោលដៅចម្បងៗនាថ្ងៃនេះ គឺពិតជាបានកើតចេញយ៉ាងប្រាកដ ពីការខិតខំប្រឹងប្រែង និង ការលះបង់ពេលវេលាផ្ទាល់ខ្លួនរបស់ក្រុមការងារ ក្នុងការបំពេញកាតព្វកិច្ច និង បន្តគាំទ្រដំណើរឈានឆ្ពោះទៅមុខជានិច្ចសម្រាប់គម្រោង FMIS ប្រកបដោយស្មារតីបុរេសកម្ម និង គោលជំហរឥតងាករេ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តជំរុញដំណើរការនៃការអនុវត្តគម្រោង FMIS ឱ្យដើរទៅមុខពីមួយជំហានទៅមួយជំហាន ដោយសម្រេចបាននូវមនុញ្ញផលសំខាន់ៗជាច្រើន ដែលជាសសរស្តម្ភចាំបាច់ ក្នុងការជួយគាំទ្រ និង ជំរុញដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាល ក៏ដូចជាស្របតាមគោល-នយោបាយ និង មគ្គទេសក៍ដឹកនាំដ៏ពិសិដ្ឋរបស់ប្រមុខរាជរដ្ឋាភិបាល ។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាមធ្យោបាយ និង ដំណោះស្រាយជាសកល បង្កើតឡើងសម្រាប់គាំទ្រស្វ័យប្រវត្តិកម្ម និង ការរួមបញ្ចូលនៃដំណើរ-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល ដែលមិនសំដៅថាសម្រាប់តែរដ្ឋាភិបាលកម្ពុជាទេដែលប្រើប្រព័ន្ធបច្ចេកវិទ្យាបែបនេះ ប៉ុន្តែសម្រាប់រដ្ឋាភិបាលនៅទូទាំងពិភពលោកប្រើប្រាស់ ដើម្បីជំរុញនូវ ការពង្រឹងវិន័យថវិកា ការបង្កើនប្រសិទ្ធភាពក្នុងការវិភាជន៍ថវិកា និង ការធានាការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយគណនេយ្យភាព, តម្លាភាព, សង្គតិភាព និង ប្រសិទ្ធភាព ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈនៅកម្ពុជា ឬ ហៅកាត់ថា FMIS បង្កើតឡើងដោយឈរលើមូលដ្ឋានជំរុញដល់ការធ្វើឌីជីថលូបនីយកម្មក្នុងវិស័យសាធារណៈលើការគ្រប់គ្រងហិរញ្ញវត្ថុ និង ការអនុវត្តថវិកាឆ្ពោះទៅវិមជ្ឈការពេញលេញទៅកាន់អង្គភាពថវិកា ដោយអនុលោមទៅតាមស្តង់ដារឧត្តមានុវត្តន៍អន្តរជាតិ ។

ខ្ញុំមានមោទនភាពយ៉ាងក្រៃលែងដែលកម្ពុជា មានFMIS ជាសមិទ្ធផលដ៏ប្រចក្ស ត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយការអនុវត្តគម្រោង FMIS ត្រូវបានគាំទ្រយ៉ាងពេញទំហឹងទាំងផ្នែកហិរញ្ញវត្ថុ និង បច្ចេសទេសពីដៃគូអភិវឌ្ឍន៍ (មានដូចជាធនាគារពិភពលោក, សហភាព-អឺរ៉ុប និង ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត) ។ ជាងនេះទៅទៀត គម្រោង FMIS ក៏បានពង្រីកវិសាលភាពរបស់ខ្លួនកាន់តែធំឡើងៗរហូតគ្របដណ្ដប់ទូទាំងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយស្របទៅតាមលក្ខខណ្ឌពេលវេលា, តម្រូវការជាក់-ស្ដែងនៃការវិវត្តសង្គម សេដ្ឋកិច្ច និង ជាពិសេស តាមលំអាននៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ការសម្រេចបានតាមគោលដៅ នៃផែនការសកម្មភាពដែលបានដាក់ចេញ, បាននិងកំពុងផ្ដល់នូវទំនុកចិត្តរឹតតែខ្លាំង ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការគាំទ្រយ៉ាងពេញទំហឹងពីដៃគូអភិវឌ្ឍន៍ ។ នេះ សបញ្ជាក់ថា យើងកាន់តែមានសមត្ថភាពគ្រប់គ្រាន់ និង មានការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីអនុវត្តការងារនេះ ឱ្យបានជោគជ័យរហូតដល់គោលដៅចុងក្រោយនៃការអនុវត្ត ។

ទន្ទឹមនឹងនេះ ដោយមើលឃើញយ៉ាងច្បាស់អំពីតម្រូវការពុំអាចខ្វះបាននៃការប្រើប្រាស់ FMIS ជាឧបករណ៍ដ៏ស័ក្ដិសិទ្ធិ ក្នុងការជំរុញ និង គាំទ្រឱ្យការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចបោះជំហានទៅមុខឥតឈប់ឈរសម្រាប់កម្ពុជា ទាំងនៅក្នុងពេលបច្ចុប្បន្ន និង នាពេលអនាគត រាជរដ្ឋាភិបាលបានកំណត់យក FMIS ជាប្រព័ន្ធផ្លូវការតែមួយគត់របស់កម្ពុជា និង បានចែងនៅក្នុងមាត្រា ១៣ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលបានកំណត់យ៉ាងច្បាស់ថា "**ការគ្រប់គ្រង ការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យលើការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ និង កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវប្រើប្រាស់ និង ឆ្លុះបញ្ចាំងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតែមួយគត់**" ។

***គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

ស្ថិតក្នុងឱកាសដ៏មហាឡោរិកនេះ ខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**, គណៈអធិបតី និង អង្គពិធី អំពីវឌ្ឍនភាពចម្បងៗ នៃការអនុវត្តគម្រោង FMIS នៅក្នុងជំហានទី១, ជំហានទី២ និង ជំហានទី៣ ក្នុងរយៈពេលជាង ១ ទសវត្សរ៍កន្លងមកនេះ ដូចតទៅ ÷

១. គិតចាប់ពីចុងឆ្នាំ ២០១៣ រហូតដល់ ចុងឆ្នាំ ២០២០ FMIS ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៃមុខងារស្នូល, ភ្ជាប់សន្ទានកម្ម, ផលិតរបាយការណ៍, អភិវឌ្ឍមុខងាថ្មី និង ដាក់ឱ្យប្រើប្រាស់នៅតាមការដ្ឋានរបស់ប្រព័ន្ធ ដូចខាងក្រោម÷

- មុខងារស្នូលចំនួន **៦** នៃ FMIS ដែលរួមមាន មុខងារវិភាជន៍ថវិកា, មុខងារការទិញ, មុខងារគណនីត្រូវសង, មុខងារគណនីត្រូវទារ, មុខងារគ្រប់គ្រងសាច់ប្រាក់ និង មុខងារសៀវភៅធំ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅ អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង នៅគ្រប់រតនាគាររាជធានី-ខេត្តទាំង ២៥

- មុខងារស្នូលចំនួន **៤** នៃ FMIS (ដោយដកមុខងារគ្រប់គ្រងសាច់ប្រាក់ និង មុខងារសៀវភៅធំចេញពីមុខងារទាំង ៦ ដែលខ្ញុំរៀបរាប់ពីខាងលើ) ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅ គ្រប់អគ្គនាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គ្រប់ក្រសួង-ស្ថាប័ន រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ និង នៅគ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥

- FMIS បានធ្វើសន្ទានកម្មជាមួយប្រព័ន្ធខាងក្រៅចំនួន **១១** និង ដាក់ឱ្យអនុវត្តមាតិកាថវិកាពេញលេញទាំង **៧ ចំណាត់ថ្នាក់** ព្រមទាំងសម្រេចបានការអភិវឌ្ឍមុខងារបន្ថែមថ្មី **២ ទៀត** គឺមុខងាររៀបចំផែនការថវិកា និង មុខងារលទ្ធកម្មពេញលេញ

- ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (EFT) នៅថ្នាក់កណ្ដាល និង របាយការណ៍ផលិតចេញពីប្រព័ន្ធចំនួន **៣៤** ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការទៅតាមតម្រូវការ នៃការដ្ឋានដែលបានប្រើប្រាស់ FMIS

- ទន្ទឹមនឹងនេះ នីតិវិធីអនុវត្តការងារតាម FMIS ទាំងស្រុង លើការបើកផ្ដល់បៀវត្ស និង ចំណាយបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ និង ចំណាយទូទាត់

ត្រង់ ដែលមានហានិភ័យទាប បានដាក់ឱ្យអនុវត្តនៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នចំនួន **៧** ។

២. ចំពោះការអនុវត្តគម្រោង FMIS ក្នុងជំហានទី៣ (ឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៥) គិតត្រឹមត្រីមាសទី២ ឆ្នាំ ២០២៣ នេះ **ក្នុងក្របខណ្ឌលទ្ធផលផែនការសកម្មភាពរួមដំណាក់កាលទី៤** យើងសម្រេចបាននូវសមិទ្ធផល និង ការត្រៀមខ្លួនលើការងារសំខាន់ៗមួយចំនួនបន្ថែមទៀត ដែលក្នុងនោះ រួមមាន÷

**ទី១-** ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ ទៅកាន់រដ្ឋបាលរាជធានី-ខេត្តទាំង **២៥** និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ចំនួន **២២** នៃក្រសួង-ស្ថាប័ន ។ ជាមួយគ្នានេះ ក្រុមការងារក៏បានធ្វើការសិក្សា រៀបចំ និង អភិវឌ្ឍរួចរាល់នូវមុខងារស្នូលនៃ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់ទៅកាន់គ្រឹះស្ថានសាធារណៈរដ្ឋបាល ។ ទន្ទឹមនឹងការដាក់ឱ្យប្រើប្រាស់មុខងារស្នូលរបស់ FMIS ក្រុមការងារក៏បានបន្តពង្រីកការដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា ទៅកាន់ក្រសួង-ស្ថាប័នចំនួន **២៥** និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង **២៥** និង មុខងារលទ្ធកម្មពេញលេញទៅកាន់គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង **២៥** ផងដែរ។

**ទី២-** ការដាក់នីតិវិធីអនុវត្តការងារតាម FMIS ទាំងស្រុង លើការបើកផ្តល់បៀវត្ស និងចំណាយបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ និង ចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការបន្ថែមដល់គ្រប់ក្រសួង-ស្ថាប័ន (លើកលែងតែក្រសួង-ស្ថាប័នកំពូលចំនួន ៣) និង ការដាក់នីតិវិធីអនុវត្តការងារលើការចំណាយថវិកាចរន្តគ្រប់មុខសញ្ញាតាម FMIS ទាំងស្រុង ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន **៨** (១.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២.ក្រសួងបរិស្ថាន, ៣.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ៤.អាជ្ញាធរសវនកម្មជាតិ, ៥.ក្រសួងធម្មការ និង សាសនា, ៦.ក្រសួងរ៉ែ និងថាមពល, ៧.ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ៨.ក្រសួងយុត្តិធម៌)។

**ទី៣-** FMIS បានធ្វើសន្ទានកម្មជាមួយប្រព័ន្ធខាងក្រៅចំនួន **៥ បន្ថែម** ដែលនៅក្នុងនោះ បានដាក់ឱ្យអនុវត្តសន្ទានកម្មជាមួយនឹងប្រព័ន្ធ PRIS រួមទាំងការអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ ជាមួយនឹង ក្រសួង-ស្ថាប័ន ចំនួន ៧ ។

**ទី៤-** កម្មវិធីកញ្ចក់ថវិកា (Budget Mirror) ដែលបង្កើតឡើងជារបាយការណ៍ឌីជីថលឆ្លាតវៃ ប្រើប្រាស់សម្រាប់ការតាមដាន និង គ្រប់គ្រងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និង កម្មវិធីតាមដានប្រតិបត្តិការ (Online Monitoring Tool) ត្រូវបានអភិវឌ្ឍ និង ប្រកាសឱ្យប្រើប្រាស់នៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់តាមដានស្ថានភាពប្រតិបត្តិការ នៅក្នុង FMIS ។

**ទី៥-** ការបង្កើតបាននូវប្រព័ន្ធ FMIS Portal **ជំនាន់ទី១** ដែលជាប្រព័ន្ធប្រើប្រាស់កម្មវិធីទូរសព្ទដៃ (Mobile Application) សម្រាប់សម្រួលដល់ការទំនាក់ទំនង និង បញ្ជូនឯកសារបានទាន់ពេលវេលា ទៅកាន់អង្គភាពមួយចំនួនដូចជា រដ្ឋបាលក្រុង/ស្រុក/ឃុំ/សង្កាត់ ដែលកន្លងមក ការអនុវត្តការងារមានការលំបាក និង មានភាពយឺតយ៉ាវ លើការងារមួយចំនួនមានដូចជា ការស្នើសុំចំណាយ, បោះពុម្ព, សាលាកបត្រ និង ការផ្ទេរឥណទានផ្សេងៗ ។ បច្ចុប្បន្នប្រព័ន្ធនេះ បានដាក់ឱ្យប្រើប្រាស់ ២ ជំហានរួចមកហើយ (ជំហានទី១ ឆ្នាំ ២០២២) និង (ជំហានទី២ ខែមីនា ឆ្នាំ២០២៣ កន្លងទៅនេះ) នៅរដ្ឋបាលក្រុងចំនួន **៦**, រដ្ឋបាលស្រុកចំនួន **១៣៦** រដ្ឋបាលឃុំចំនួន **៦៣២** និង រដ្ឋបាលសង្កាត់ចំនួន **២៨** រួមទាំងរតនាគាររាជធានី-ខេត្តទាំងអស់ ។ នៅពេលថ្មីៗនេះ ក្រុមការងារបានបន្ថែមនូវមុខងារសំខាន់ៗមួយចំនួនទៀតរួចរាល់ ដើម្បីឱ្យកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់, កាន់តែបំពេញបានតាមតម្រូវការការងារជាក់ស្តែង និង ស្របតាមស្ថានភាពនៃការវិវត្តនៃបច្ចេកវិទ្យាព័ត៌មាន និង ទស្សនៈវិស័យរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមរបស់កម្ពុជាដែលតែងប្រកាន់ខ្ជាប់នូវទស្សនៈកែទម្រង់ដ៏មុតស្រួច និង បានលើកឡើងថា “**កែទម្រង់ គឺរស់, មិនកែទម្រង់ គឺស្លាប់**” បានសេចក្តីថាយើងគ្មានជម្រើសអ្វីល្អជាងនេះទៀតទេ ក្រៅពីធ្វើការកែទម្រង់នោះឡើយ ហើយការទម្រង់នេះទៀតសោតត្រូវ “***កែឱ្យចំគោលដៅ កែឱ្យមានប្រសិទ្ធភាព និង កែឱ្យមានចីរភាព***” ។

*គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

សរុបជារួមនៃវិសាលភាព ចាប់តាំងពីការអនុវត្តជំហានទី១ រហូតមកដល់ថ្ងៃនេះ យើងកំណត់បានថា ការដ្ឋានដែលកំពុងប្រើប្រាស់ FMIS សរុបមានចំនួន **១៦៦ ការដ្ឋាន**, មុខងារប្រព័ន្ធដែលកំពុងដំណើរការមានចំនួន **៨ មុខងារ**, សន្ទានកម្មជាមួយប្រព័ន្ធខាងក្រៅមានចំនួន **១៦ ប្រព័ន្ធ**, របាយការណ៍ផលិតចេញពីប្រព័ន្ធសរុបមានចំនួន **៦១ របាយការណ៍**, សិក្ខាកាមទទួលការបណ្តុះបណ្តាលមានចំនួន **៣ ៤៦២ រូប** និង អ្នកប្រើប្រាស់ប្រព័ន្ធសរុបមានចំនួន **២ ៨៤០ រូប** ។ ដោយឡែកសម្រាប់ការដ្ឋានដែលកំពុងប្រើប្រាស់ **FMIS Portal ជំនាន់ទី១** ទាំងជំហានទី១ និង ជំហានទី២ មានចំនួន **៨០២ ការដ្ឋាន** និង អ្នកប្រើប្រាស់ប្រព័ន្ធនេះសរុបមានចំនួន **១ ៥៥០ រូប** ។

ពិធីប្រកាសនៅក្នុងថ្ងៃនេះដែរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នឹងផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងការប្រកាសបន្ថែមនូវសមិទ្ធផលថ្មីៗ ដែលក្រុមការងារគ្រប់គ្រងគម្រោង FMIS នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបានពាក់ព័ន្ធនឹង÷

ទី១. ការពង្រីកការដ្ឋានដាក់ឱ្យប្រើប្រាស់មុខងារស្នូលនៃ **FMIS** ជាផ្លូវការ

ទី២. ការពង្រីកការអនុវត្តនីតិវិធីចំណាយថវិកាចរន្ត ដែលមិនមានធានាចំណាយដោយឡែក តាម **FMIS** ទាំងស្រុង

ទី៣. ការពង្រីកការដ្ឋានបន្ថែមថ្មីសម្រាប់ការដាក់ឱ្យអនុវត្តសន្ទានកម្មជាមួយនឹងប្រព័ន្ធ PRIS និង

ទី៤. ការពង្រីកការដ្ឋានបន្ថែមថ្មីសម្រាប់ការដាក់ឱ្យប្រើប្រាស់ **FMIS Portal ជំនាន់ទី១** ។

ការសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ដែលខ្ញុំបានរាយការណ៍ជូន អង្គពិធីពីខាងលើ គឺជាការកើតចេញពីឆន្ទៈដ៏មោះមុតរបស់យើងទាំងអស់គ្នា និង បានឆ្លងកាត់នូវប្រវត្តិដ៏វែងឆ្ងាយជាមួយនឹងឧបសគ្គជាច្រើន អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ។ យើងកត់សម្គាល់ឃើញថា បើទោះជាមានបញ្ហាប្រឈម និង ឧបសគ្គធំៗជាច្រើន ទាំងលើកិច្ចការគ្រប់គ្រង និងការងារអនុវត្តគម្រោង ប៉ុន្តែក្រុមការងារបានសហការពួតដៃគ្នាយ៉ាងប្រទាក់ក្រឡា ដើម្បីកែប្រែ

បញ្ហាប្រឈម ឱ្យទៅជាកាលានុវត្តភាពដ៏វិសេសក្នុងការជំរុញឱ្យសម្រេចនូវសមិទ្ធផលធំៗទាំងអស់នេះ មុនផែនការ និង មុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដើម្បីបង្ហាញឱ្យឃើញច្បាស់អំពីសមិទ្ធផលរូបីយ៍ជាក់ស្តែងដ៏ធំធេង ក្នុងចំណោមសមិទ្ធផលផ្សេងទៀតរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅជំរុញ និង ពន្លឿនដល់ការអនុវត្តថវិកានៅទូទាំងប្រទេស ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋ-មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង មាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ជាសេនាធិការដ៏រឹងមាំ ។

ខ្ញុំពិតជាកោតស្ងប់ស្ញែង និង វាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងដ៏ម៉ឺងម៉ាត់របស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS ពិសេស លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS ដែលសហការជាមួយគ្រប់តួអង្គពាក់ព័ន្ធ, ទាំងនៅការដ្ឋានរដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីជំរុញដល់ការអនុវត្តគម្រោង FMIS ដែលកិច្ចការនេះពិតជាបានផ្តល់នូវជវភាពជំរុញខ្លាំងដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់កម្ពុជាប្រកបដោយថាមភាពយ៉ាងពិតប្រាកដ ។

ជាចុងបញ្ចប់, ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដែលជា "**អ្នកគាំទ្រនាំមុខ**" ចំពោះការអនុវត្តគម្រោង FMIS និង ជា "**អគ្គមេបញ្ជាការដ៏ឆ្នើម និង ឈ្លាសវៃក្នុងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ**" និង តែងតែផ្តល់នូវភាពជាអ្នកដឹកនាំដ៏ក្លៀវក្លា ប្រកបដោយឆន្ទៈស្នេហាជាតិ តម្កល់ប្រយោជន៍សម្ហូហភាពជាធំ ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចសម្រេចបាននូវសមិទ្ធផលទាំងអស់នេះក្នុងក្របខណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់គាំទ្រដល់ការពង្រឹងប្រសិទ្ធភាព និង គុណភាព នៃការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ កាន់តែប្រសើរឡើង ជូនដល់ប្រជាពលរដ្ឋ និង ភាគីពាក់ព័ន្ធនានា ។

ខ្ញុំសូមជូនពរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី, ឯកឧត្តម, លោកជំទាវ, លោក លោកស្រី** ដែលមានវត្តមាននៅក្នុងពិធីនេះ និង **តាមប្រព័ន្ធវីដេអូ** សូមទទួលបាននូវសុខភាពល្អ, មានសុភមង្គលក្នុងក្រុមគ្រួសារ និង ជោគជ័យតាមភារកិច្ចរៀងៗខ្លួន ។

*សូមអរគុណ !*